**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជសដ

ភាគីដាក់ឯកសារ: លោក ខៀវ សំផន

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: **បារាំង**

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៣ ខែ តុលា ឆ្នាំ ២០១៤

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 03-Oct-2014, 13:56
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយសាលាដំបូង **សាធារណៈ/Public**

ប្រភេទនៃចំណាត់

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

# សំណើជាបន្ទាន់សុំឲ្យពិចារណាឡើងវិញ លើដីកាកំណត់កាលបរិច្ឆេទសម្រាប់ សវនាការលើអង្គសេចក្ដីក្នុងសំណុំរឿង ០០២/០២

ដាក់ដោយ៖

**សហមេធាវីការពារក្ដីលោក ខៀវ សំផន**

លោក គង់ សំអុន

លោកស្រី Anta GUISSÉ

លោក Arthur VERCKEN

**អ្នកជំនួយការ**

លោកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

កញ្ញា Soumeya MEDJEBEUR

លោក Pierre TOUCHE

ផ្ញើជូន៖

**អង្គជំនុំជម្រះតុលាការសាលាដំបូង**

ចៅក្រម និល ណុន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យូ ឧត្តរា

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ា សុខន

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

កញ្ញា អ៊ូច ស្រីផាត
កញ្ញា Cécile ROUBEIX
លោក BOSSIS Clément

**មេធាវីនៃដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់**

**ក្រុមមេធាវីខាងការពារក្ដីរបស់លោក នួន ជា**

# សូមគោរពអង្គជំនុំជម្រះសាលាដំបូង

១. តាមរយៈសេចក្តីសម្រេចចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៤ (“សេចក្តីសម្រេច”) អង្គជំនុំជម្រះបានច្រានចោលការស្នើសុំរបស់លោក ខៀវ សំផន ដែលស្នើសុំពន្យារការចាប់ផ្តើមសំណុំរឿង ០០២/០២ ដោយរង់ចាំសាលដីកាស្ថាពរពីអង្គជំនុំជម្រះតុលាការកំពូលសិន (“តុលាការកំពូល”)។[1] នៅថ្ងៃដដែលនោះ អង្គជំនុំជម្រះបានចេញ *“ដីកាកំណត់កាលបរិច្ឆេទសម្រាប់សវនាការលើអង្គសេចក្តីក្នុងសំណុំរឿង០០២/០២”* [2] (“ដីកា”) ដែលកំណត់ផ្នែកទីមួយនៃកិច្ចពិភាក្សាដេញដោល ពីថ្ងៃទី ១៧ ខែតុលា ដល់ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤។[3]

២. ដូចមេធាវីការពារក្តីបានបញ្ជាក់ជាច្រើនដងរួចមកហើយ នៅក្នុងពេលថ្មីៗនេះ គឺនៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៤ នៅក្នុងសវនាការបឋមសម្រាប់សំណុំរឿង ០០២/០២[4] បើគិតតាមលក្ខណៈសត្យានុម័ត វាមិនអាចទៅរួចទេក្នុងការរៀបចំការពិភាក្សាដេញដោលសម្រាប់សំណុំរឿង ០០២/០២ ផង និងតាក់តែងសារណាបណ្តឹងបណ្តឹងសាទុក្ខផង ក្នុងជាមួយគ្នានោះឡើយ។ ម៉្យាងទៀត ស្ថានភាពនេះ មិនអាចឲ្យ លោក ខៀវ សំផន ចូលរួមបានពេញលេញ នៅក្នុងការការពារក្តីឡើយ។ លើសពីនោះទៀត នៅមានសំណួរច្រើនណាស់ដែលត្រូវចោទឡើងស្តីពីលក្ខខណ្ឌក្នុងការរៀបចំសំណុំរឿង ០០២/០២ ហើយសំណួរខ្លះមានទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងខ្លឹមសារនៃសារណាបណ្តឹងសាទុក្ខនៃភាគី។

៣. លោក ខៀវសំផន ក៏បានស្នើសុំដល់អង្គជំនុំជម្រះឲ្យពិចារណាលើដីការបស់ខ្លួនឡើងវិញ ដោយមិនកំណត់កាលបរិច្ឆេទនៃការចាប់ផ្តើមសំណុំរឿង ០០២/០២ មុនកាលបរិច្ឆេទនៃការដាក់សារណាបណ្តឹងសាទុក្ខ របស់មេធាវីការពារក្តីនៅក្នុងសំណុំរឿង ០០២/០១ ឡើយ។ សំណើ

---

[1] សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំពន្យារការចាប់ផ្តើមសំណុំរឿង ០០២/០២ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៤ **E314/5** (“សេចក្តីសម្រេច”) ។

[2] ដីកាកំណត់កាលបរិច្ឆេទសម្រាប់សវនាការលើអង្គសេចក្តីក្នុងសំណុំរឿង០០២/០២ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៤ **E316** (“ដីកា”)

[3] ដីកា **E316** ទំព័រ៤ និងឧបសម្ព័ន្ធ **E316.1**.

[4] ប្រតិចារឹកសវនាការ (“ប្រតិចារឹក”) ចុះថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ ២០១៤ **E1/240.1** ទំ ៣៨ បន្ទាត់ទី១៦ រហូតដល់ ទំ ៣៩ បន្ទាត់ទី១៧។

នេះត្រូវបានធ្វើឡើង ដោយអនុវត្តតាមយុត្តិសាស្ត្រនៃអង្គបុរេជំនុំជម្រះ និងតុលាការកំពូល ដែលសុទ្ធតែបានវិនិច្ឆ័យជាបន្តបន្ទាប់ថា អ.វ.ត.ក អាច ពិចារណាឡើងវិញលើសេចក្តីសម្រេច របស់ខ្លួន នៅពេលដែលមានមូលដ្ឋានស្របច្បាប់ (*« legitimate basis »*)[5] ក្នុងករណីដែល សេចក្តីសម្រេចពេលមុនៗមានកំហុស ឬបង្កឲ្យមានភាពអយុត្តិធម៌ ឬនៅពេលដែលការ ពិចារណាឡើងវិញនោះ មិនផ្ទុយទៅនឹងផលប្រយោជន៍នៃយុត្តិធម៌។[6] មេធាវីការពារក្តីសូម យល់ស្របថា ត្រូវពិចារណាលើដីកានេះឡើងវិញ ពីព្រោះថា ម្យ៉ាងការរៀបចំសំណុំរឿងពីរ វគ្គក្នុងពេលដំណាលគ្នា អាចបង្កឲ្យមានព្យសនកម្មដល់ការការពារក្តីលោក ខៀវ សំផន ប្រកបដោយប្រសិទ្ធភាព (I) ហើយម្យ៉ាងទៀត វាជា ប្រយោជន៍នៃយុត្តិធម៌ដែលត្រូវដោះ ស្រាយបញ្ហានីតិវិធីទាំងអស់ មុននឹងចាប់ផ្តើមសំណុំរឿង ០០២/០២ (II)។

## I. អំពីការដែលក្រុមមេធាវីការពារក្តីមិនអាចរៀបចំសំណុំរឿងពីរវគ្គក្នុងពេលដំណាលគ្នាដោយឥតបង្កព្យសនកម្មដល់ លោក ខៀវ សំផន

៤. ដោយមានបំណងចង់បានភាពស៊ីសង្វាក់គ្នា និងការសន្សំពេលវេលាក្នុងនីតិវិធីតុលាការ ចំពោះ មេធាវីការពារក្តី វាជាការសមស្រប ប្រសិនបើសំណុំរឿង ០០២/០២ មិនចាប់ផ្តើមមុនពេល តុលាការកំពូលសម្រេចលើបណ្តឹង និងសម្អាងសាទុក្ខទាំងអស់ ដែលបានលើកឡើងដោយ មេធាវីការពារក្តី ប្រឆាំងនឹងការវិនិច្ឆ័យផ្តន្ទាទោស នៅថ្ងៃទី៧ ខែសីហា ឆ្នាំ ២០១៤ ("សាលក្រម")។ ជាពិសេសនៅក្នុងសម្អាងហេតុ អង្គជំនុំជម្រះបានបដិសេធថា ៖ *"គេអាច ប៉ាន់ស្មានដោយសមហេតុផលបានថា អង្គជំនុំជម្រះតុលាការកំពូលប្រាកដជានឹងចេញសាល ដីកាលើសំណុំរឿង ០០២/០១ នៅមុនការជំនុំជម្រះក្តីណាមួយក្នុងសំណុំរឿង០០២/០២ ត្រូវ បានបញ្ចប់។ ដូចនេះ ភាគីទាំងអស់នឹងមានឱកាស នៅពេលនោះដាក់សារណាទៅអង្គជំនុំ ជម្រះសាលាដំបូង ពាក់ព័ន្ធនឹងសម្អាងហេតុណាមួយ ដែលអង្គជំនុំជម្រះតុលាការកំពូល សម្រេច ដែលមានការពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២។"*[7]

---

[5] សេចក្តីសម្រេចលើពាក្យសុំពិចារណាសារជាថ្មីអំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះ ដោយខ្លួនឯង ថ្ងៃទី ២៨ ខែសីហា ឆ្នាំ ២០០៨ **C22/I/68** កថាខណ្ឌ 25។

[6] សេចក្តីសម្រេច E314/5 កថាខណ្ឌទី៧។

[7] សេចក្តីសម្រេច **E314/5** កថាខណ្ឌ ៧។

៥. មេធាវីការពារក្តីគ្មានជម្រើសអ្វីផ្សេងក្រៅតែពីទទួលយកជំហរ របស់អង្គជំនុំជម្រះលើចំណុចនោះឡើយ។ មេធាវីការពារក្តីសុំរក្សាសំណើបន្ទាប់បន្សំរបស់ខ្លួនសុំប្តឹងជិតចិត្ត និង ចាត់តាំងក្រុមប្រឹក្សាអង្គជំនុំជម្រះថ្មី ដូចដែលបានលើកឡើងនៅក្នុងសំណើសុំ E314/1 ចុះថ្ងៃទី ២៥ ខែសីហា ឆ្នាំ ២០១៤។[8] ក៏ប៉ុន្តែ មេធាវីការពារក្តី សូមកត់សម្គាល់ថា អង្គជំនុំជម្រះបានទទួលស្គាល់យ៉ាងច្បាស់ក្រឡែតថា សាលដីកានៃអង្គជំនុំជម្រះតុលាការកំពូលអាចនឹងមានឧប្បត្តិហេតុទៅលើសំណុំរឿង ០០២/០២។

**ដីកានេះអាចបង្កផលប៉ះពាល់ដល់ការការពារក្តី លោក ខៀវ សំផន នៅក្នុងនីតិវិធីបណ្តឹងសាទុក្ខនៃសំណុំរឿង ០០២/០១ និងនៅក្នុងសំណុំរឿង ០០២/០២**

៦. មេធាវីការពារក្តីបានដាក់បណ្តឹងសាទុក្ខរបស់ខ្លួន នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤ ដែលនៅក្នុងបណ្តឹងនោះ មេធាវីការពារក្តី បានសុំឱ្យបដិសេធសាលក្រម និងស្នើសុំលើកលែងការចោទប្រកាន់លើរូប លោក ខៀវ សំផន។[9] ក្នុងចំណោមសម្អាងហេតុសំខាន់ៗនៃបណ្តឹងសាទុក្ខនេះ មានបែបបទនៃការធ្វើសេចក្តីសន្និដ្ឋានទុកមុនរបស់អង្គជំនុំជម្រះទៅលើអង្គហេតុដែលមានក្នុងសំណុំរឿង ០០២/០២ និងការភ័ន្តច្រឡំរបស់អង្គជំនុំជម្រះទៅលើការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ លោក ខៀវ សំផន ជាពិសេសនៅក្នុងសេចក្តីសន្និដ្ឋានស្តីពីសហឧក្រិដ្ឋកម្មរួម។ បណ្តឹងសាទុក្ខនេះ គឺជាចំណុចអាទិភាព បើនិយាយពីយុទ្ធសាស្ត្ររបស់មេធាវីការពារក្តី។ ពីព្រោះថា សេចក្តីសន្និដ្ឋានលើអង្គហេតុ និងអង្គច្បាប់ ទៅលើការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់លោក ខៀវ សំផន នៅក្នុងសំណុំរឿង ០០២/០១ គឺជាគោលដៅដ៏សំខាន់សម្រាប់កំណត់ការទទួលខុសត្រូវ របស់

[8] សំណើរបស់ លោក ខៀវ សំផន សុំឱ្យពិនិត្យឡើងវិញពីភាពចាំបាច់ក្នុងការរង់ចាំសាលក្រមក្នុងសំណុំរឿង ០០២/០១ ចូលជាស្ថាពរ មុននឹងចាប់ផ្តើមការជំនុំជម្រះសំណុំរឿង ០០២/០២ និង សុំឱ្យពិនិត្យឡើងវិញពីការចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះថ្មីមួយ **E314/1** ថ្ងៃទី ២៥ ខែសីហា ឆ្នាំ ២០១៤ កថាខណ្ឌ៤៨ និងកថាខណ្ឌបន្តបន្ទាប់។

[9] បណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី លោក ខៀវ សំផន ប្រឆាំងនឹងសាលក្រមសម្រេចក្នុងសំណុំរឿង ០០២/០១ ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤ **E313/2/1**

លោក នៅក្នុងសំណុំរឿង ០០២/០២។

៧. ជាស្វ័យប្រវត្តិ គោលដៅរបស់មេធាវីការពារក្តី គឺធ្វើយ៉ាងណាឲ្យសេចក្តីសន្និដ្ឋាននៃអង្គជំនុំជម្រះ ត្រូវបដិសេធដោយតុលាការកំពូល។ បើគ្មានចំណុចទាំងនោះទេ មធ្យោបាយខាងការពារក្តី សម្រាប់បង្ហាញនៅក្នុង សំណុំរឿង ០០២/០២ ប្រាកដជាមានតិចតួចបំផុត។ វានឹងមិនសូវមានអត្ថន័យប៉ុន្មានឡើយ ប្រសិនបើមេធាវីការពារក្តីមិនអាចពង្រីកការទិតៀនរបស់ខ្លួនទៅលើសាលក្រម ឲ្យបានពេញលេញ និងទាំងស្រុង នៅក្នុងសារណាបណ្តឹងសាទុក្ខរបស់ខ្លួនទេនោះ។

៨. ទោះបីជាអង្គជំនុំជម្រះ បានលើកឡើងនៅក្នុងដីការបស់ខ្លួនថាបានលើកឡើងថា *"តម្រូវការធនធានជាច្រើនរបស់ភាគីនាពេលបច្ចុប្បន្នដើម្បីរៀបចំសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ និងសារណានៃបណ្តឹងសាទុក្ខ ក្នុងសំណុំរឿង ០០២/០១"* ដោយកំណត់ពេលចាប់ផ្តើមនៃការពិភាក្សាលើអង្គសេចក្តី នៅថ្ងៃទី១៧ ខែតុលា យ៉ាងណាក្តី តែអង្គជំនុំជម្រះមិនបានទៅដល់ចុងបញ្ចប់នៃការរិះគិតរបស់ខ្លួនឡើយ។ ពីព្រោះថា ការចាត់ទុកថាមានតែបណ្តឹងសាទុក្ខតែមួយគត់ដែលតម្រូវឲ្យមានមធ្យោបាយច្រើនសន្ធឹកសន្ធាប់ វាជាការមិនត្រឹមត្រូវឡើយ។

៩. ជាការគួរឲ្យស្តាយ សមាសភាពនៃក្រុម មេធាវីការពារក្តីមិនអាចពង្រីកបន្ថែមបានឡើយ រីឯម៉ោងពេលបំពេញការងារក៏មិនអាចពង្រីកបានដូចគ្នា។ វាគ្មានប្រយោជន៍ទេ ដែលអង្គជំនុំជម្រះប្រកាសថា បានរៀបចំ *"ប្រតិទិនសវនាការស្រាលជាងមុន"* តែអង្គជំនុំជម្រះមិនគិតទេថា ការបំពេញការងារនៅក្នុងសវនាការ គ្រាន់តែជាផ្នែកតូចមួយដែលគេមើលឃើញ រីឯការងាររៀបចំត្រៀមសវនាការមានច្រើនជាងនេះទៅទៀត ដែលអង្គជំនុំជម្រះក៏បានដឹងថាបានធ្លាប់លើកឡើងពីចំណុចនេះពីពេលមុនទៀតផង។[10] ប៉ុន្តែការងាររៀបចំនៅក្រៅសវនាការនេះមិនអាចប្រព្រឹត្តទៅបានត្រឹមត្រូវទេ ប្រសិនជាគេត្រូវធ្វើឡើងស្របពេលជាមួយនឹងការសរសេរសារណាបណ្តឹងសាទុក្ខ ដែលតម្រូវឲ្យមានការរៀបចំច្បាស់លាស់ ការប្រមូលផ្តុំអារម្មណ៍ និងការស្រាវជ្រាវ។ សូមរំឭកថា

[10] ប្រតិចារឹក ចុះថ្ងៃទី ១១ ខែធ្នូ ឆ្នាំ ២០១៣ **E1/238.1** ពីទំព័រ ៩៩ បន្ទាត់ទី៧ ដល់ទំព័រ ១០០ បន្ទាត់ទី១។ សំណើជាបន្ទាន់សុំឲ្យពិចារណាការឡើងវិញ លើដីកាកំណត់កាលបរិច្ឆេទសម្រាប់សវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០២

សាលក្រមមានចំនួន ៧៧៦ ទំព័រ និង ៣២៩៨ កំណត់ជើងទំព័រ។ សូមរំឭកបន្ថែមទៀតថា អង្គជំនុំជម្រះខ្លួនឯងផ្ទាល់បានបញ្ជាក់ថា មិនអាចសរសេរសាលក្រមនេះផង និងរៀបចំសវនាការនៃសំណុំរឿង ០០២/០២ ផង ក្នុងពេលដំណាលគ្នាបានទេ![11] ដើម្បីសម្រាយន័យសេចក្ដីរបស់ លោកចៅក្រម LAVERGNE ដែលបានពន្យល់ថា ពេលចាំបាច់សម្រាប់អង្គជំនុំជម្រះក្នុងការតាក់តែងសាលក្រម ជាពេលដែលមិនអាចរឹតបន្តឹងបានឡើយ គឺថា *"យើងត្រូវមានលទ្ធភាពក្នុងការផ្តោតអារម្មណ៍យ៉ាងស៊ីជម្រៅទៅលើបញ្ហាចម្រូងចម្រាស ហើយដែលត្រូវការពេលវេលានោះ។"*[12]

១០. ដូច្នេះ តាមរយៈដីការបស់ខ្លួន ដែលកំណត់ពេលវេលាចាប់ផ្តើមកិច្ចពិភាក្សាដេញដោលសម្រាប់ សំណុំរឿង ០០២/០២ មុនពេលដាក់សារណាបណ្តឹងសាទុក្ខ នេះ អង្គជំនុំជម្រះកំពុងតែដាក់មេធាវីការពារក្តី ឱ្យស្ថិតក្នុងអលទ្ធភាពក្នុងការការពារផលប្រយោជន៍ លោក ខៀវ សំផន ឱ្យបានត្រឹមត្រូវយ៉ាងច្បាស់ក្រឡែត ។ អាក្រក់ជាងនោះទៀត អង្គជំនុំជម្រះបានដាក់ឱ្យមេធាវីការពារក្តី ប្រឈមមុខទៅនឹងជម្រើសដែលមានព្យសនកម្មសម្រាប់ជនជាប់ចោទ ៖ សរសេរសារណាបណ្តឹងសាទុក្ខបានត្រឹមត្រូវ តែមិនមានពេលរៀបចំសវនាការក្នុងសំណុំរឿង ០០២/០២ ឬសរសេរសារណាមិនបានល្អ និងមិនជាទីពេញចិត្ត ហើយផ្តោតអារម្មណ៍ទៅលើសំណុំរឿង ០០២/០២ ជាមួយនឹងការការពារក្តីមួយដែលមិនពេញលេញ ដោយសារតែទទួលឥទ្ធិពលពីសាលក្រម លើសំណុំរឿង ០០២/០២ នេះ។

១១. វាជារឿងអយុត្តិធម៌ដែលដាក់ លោក ខៀវ សំផន និងមេធាវីការពារក្តីរបស់គាត់ ឱ្យប្រឈមមុខទៅនឹងជម្រើសបែបនេះ។ ក្រមសីលធម៌នៃមេធាវី ក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានចែងថា មេធាវី *« shall respect and abide by the principle of integrity and honesty »*[13] and *« make efforts for true faire trial,*

[11] ជាឧទាហរណ៍ ប្រតិចារឹក ចុះថ្ងៃទី ១១ ខែធ្នូ ឆ្នាំ ២០១៣ **E1/238.1** ពីទំព័រ ៩៩ បន្ទាត់ទី៧ ដល់ទំព័រ ១០០ បន្ទាត់ទី១។ ប្រតិចារឹក ចុះថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ២០១៣ **E1/238.2** ពីទំព័រ ១១១ បន្ទាត់ទី៤ ដល់ទំព័រ ១១៣ បន្ទាត់ទី៤។

[12] ប្រតិចារឹក ចុះថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ២០១៣ **E1/238.2** ទំព័រ ១១១ បន្ទាត់ទី១៧-១៩

[13] ក្រមសីលធម៌នៃមេធាវីដែលបានចុះក្នុងបញ្ជីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៦។

*law compliance and due process. »*[14]។ សំណើយើងខ្ញុំនេះ ត្រូវបានធ្វើឡើង ដោយអនុវត្តតាមគោលការណ៍ទាំងនេះ។ វាជាការការទទួលខុសត្រូវរបស់ មេធាវី លោក ខៀវ សំផន ដែលត្រូវជូនដំណឹងដល់លោកអំពី ហានិភ័យដល់ការការពារក្តីរបស់លោក ក្នុងការជ្រើសបែបនេះ និងត្រូវធ្វើយ៉ាងណាឲ្យអង្គជំនុំជម្រះយល់ពីបញ្ហាប្រឈមទាំងនេះ ដើម្បី ឲ្យមានឡើងវិញនូវលក្ខខណ្ឌនានានៃការកាត់សេចក្តីប្រកបដោយយុត្តិធម៌។

១២. បើគិតតាមទស្សនៈសីលធម៌វិជ្ជាជីវៈ មេធាវីរបស់ លោក ខៀវ សំផន មានកាតព្វកិច្ចក្នុងការការពារឲ្យបានប្រសើរបំផុត ប្រកបដោយភក្តីភាព ដោយឯករាជ្យភាព និងមិនតម្រូវចិត្តអ្នកណាម្នាក់ នូវអត្ថប្រយោជន៍របស់កូនក្តីខ្លួន។ នេះជាកាតព្វកិច្ចដែលស្តែងចេញពីអត្ថបទច្បាប់ជាតិ និងអន្តរជាតិ[15] ពាក់ព័ន្ធទៅនឹងសីលធម៌វិជ្ជាជីវៈរបស់មេធាវី។ ជាឧទាហរណ៍ បទបញ្ជាផ្ទៃក្នុងរបស់គណៈមេធាវីក្រុងប៉ារីស ដែលមេធាវីអន្តរជាតិទាំងពីររបស់លោក ខៀវ សំផន ស្ថិតនៅក្រោមឱវាទនោះ កំណត់ថែមទៀតថា *"មេធាវីមានកាតព្វកិច្ចការពារផលប្រយោជន៍របស់កូនក្តីខ្លួនឲ្យបានប្រសើរបំផុតច្រើនជាងផលប្រយោជន៍ផ្ទាល់ខ្លួនទៅទៀត"* [16]។ ចំពោះមេធាវីរបស់ លោក ខៀវ សំផន វិញ មកដល់ដំណាក់កាលនៃនីតិវិធីនេះ និងដោយគិតដល់ផលវិបាកលើការបន្តសំណុំរឿង ០០២ផង ការការពារផលប្រយោជន៍របស់កូនក្តីឲ្យបានប្រសើរបំផុត គឺត្រូវធានាឲ្យបាននូវការបំពេញរាល់ការងារចាំបាច់ទាំងអស់សម្រាប់ការដាក់សារណាបណ្តឹងសាទុក្ខ ឲ្យបានគ្រប់ជ្រុងជ្រោយ និងប្រកបដោយគុណភាព។

## ដីកា អាចរាំង លោក ខៀវ សំផន មិនឲ្យចូលរួមបានពេញលេញក្នុងការការពារក្តីរបស់លោក

[14] *Ibidem*, article 38.

[15] ជាឧទាហរណ៍ ៖ គោលការណ៍មូលដ្ឋានពាក់ព័ន្ធនឹងតួនាទីរបស់គណៈមេធាវី អនុម័តដោយសមាជលើកទី៨នៃអង្គការសហប្រជាជាតិ ដើម្បីបង្ការឧក្រិដ្ឋកម្ម និងការប្រព្រឹត្តបទល្មើស ដែលបានប្រព្រឹត្តទៅ នៅទីក្រុង ឡាហាវ៉ាន (គុយបា) ពីថ្ងៃទី២៧ ខែសីហា ដល់ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ ១៩៩០ កថាខណ្ឌ ១២-១៥ ។ ធម្មនុញ្ញនៃគោលការណ៍សំខាន់ៗនៃមេធាវីអឺរ៉ុប និងច្បាប់ក្រមសីលធម៌មេធាវីអឺរ៉ុប ក្រុមប្រឹក្សាគណៈមេធាវីអឺរ៉ុប ឆ្នាំ ២០០៨ ទំព័រ៥-៨។

[16] បទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវីក្រុងប៉ារីស មាត្រា ២១.២.៧

១៣. ទោះជាក្នុងសំណុំរឿង ០០២/០១ ក៏ដូចជាសំណុំរឿង ០០២/០២ លោក ខៀវ សំផន ត្រូវបានចោទប្រកាន់អំពីបទឧក្រិដ្ឋដ៏ធ្ងន់ធ្ងរបំផុត។ លោកមានសិទ្ធិចូលរួមយ៉ាងសកម្ម ក្នុងការការពារក្តីរបស់លោក។ យើងគួររំឭកនៅទីនេះ នូវយុត្តិសាស្ត្រនៃតុលាការព្រហ្មទណ្ឌអន្តរជាតិដើម្បីប្រទេសយូហ្គោស្លាវី ក្នុងរឿងក្តីរបស់ *Mladic* ដែលក្នុងរឿងក្តីនោះ ចៅក្រមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិដើម្បីប្រទេសយូហ្គោស្លាវីបានចាត់ទុកថា « *the division of time and attention that would be required of the Accused to participate in his defence to both cases could render his participation less effective and also necessitate a slower pace of proceedings for both trials* »[17]។ ដូចមេធាវីការពារក្តីធ្លាប់បានបញ្ជាក់ក្នុងសារណាមុនៗរួចហើយ[18] ៖ "*សច្ចភាពនេះ ពិតជាត្រឹមត្រូវក្នុងករណីដំណើរការនីតិវិធីជាច្រើនក្នុងពេលតែមួយ ទោះបីជាដំណើរការនីតិវិធីទាំងនោះ ប្រព្រឹត្តទៅបែបណាក៏ដោយ ហើយសច្ចភាពនេះរឹតតែសមស្រប នៅក្នុងសំណុំរឿង ០០២ ដោយហេតុថា ជនជាប់ចោទទាំងពីររូបនេះ ម្នាក់មានអាយុ ៨៣ ឆ្នាំ និងម្នាក់ទៀតមានអាយុ ៨៧ ឆ្នាំ។*" ហើយលើសពីនោះ "*វានៅតែសមស្របក្នុងក្របខណ្ឌនៃការការពារខ្លួន ដែលធានាដោយមេធាវីតែមួយក្រុម។*"

១៤. ចាប់ពីមានសំណេរនេះតមក ជំហររបស់មេធាវីការពារក្តីត្រូវបានពង្រឹងដោយការដែលការងារដែលបានអនុវត្តរួចសម្រាប់បណ្តឹងសាទុក្ខ បង្ហាញឲ្យឃើញថា នឹងត្រូវការកម្លាំងនៃក្រុមការងារទាំងមូលរបស់មេធាវីការពារក្តី (ដែលគួរឲ្យស្តាយ មានចំនួនតិច) សម្រាប់ការតាក់តែងសារណាបណ្តឹងសាទុក្ខ។ ការងារស្រាវជ្រាវ តាក់តែងគំនិតសំយោគ និងជម្រើសយុទ្ធសាស្ត្រ ត្រូវការពេលវេលា -ក្រៅពីមធ្យោបាយធនធានមនុស្សចាំបាច់ - ចំពោះ លោក ខៀវ សំផន ដែលជាមនុស្សមានវ័យចំណាស់នោះក៏មានន័យផងដែរថា ត្រូវមានពេលវេលា និងថាមពលចាំបាច់សម្រាប់សិក្សាលើឯកសារការងារធ្វើការអធិប្បាយ និងពិភាក្សាជាមួយសមាជិកក្រុមការពារក្តីរបស់គាត់។

[17] *Le Procureur c. Ratko Mladic*, affaire n°IT-09-92-PT, *Decision on Consolidated Prosecution Motion to Sever the Indictment, to Conduct Separate Trials, and to Amend the Indictment*, 13 octobre 2011, par. 31.

[18] បណ្តឹងសាទុក្ខភ្លាមៗរបស់មេធាវីការពារក្តីលោក ខៀវ សំផន ប្រឆាំងនឹងសេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម លើសំណុំរឿង ០០២ និងលើការកំណត់វិសាលភាពនៃសំណុំរឿង ០០២/០២ ថ្ងៃទី៥ ខែឧសភា ឆ្នាំ ២០១៤ **E301/9/1/1/1**កថាខណ្ឌទី ៤៤

១៥. វាជាការសំខាន់ណាស់ក្នុងការគូសបញ្ជាក់នៅទីនេះថា *"ប្រតិទិនសវនាការសម្រាល"* នៅក្នុងអំឡុងពេលតាក់តែងសារណាបណ្តឹងសាទុក្ខ ដែលកំណត់នៅក្នុងដីកា គ្រាន់តែជានុយបញ្ឆោតប៉ុណ្ណោះ។ ពីព្រោះថា ប្រតិទិននេះ គ្រោងធ្វើសវនាការបីថ្ងៃ ទៅតាមម៉ោងពេល ដូចក្នុងសំណុំរឿង ០០២/០១ ដដែល ដែលត្រូវគ្នាតិច ឬច្រើនទៅនឹងការបើកសវនាការ បី ឬបួនថ្ងៃ ដូចធ្លាប់ធ្វើឡើងនៅក្នុង សំណុំរឿង ០០២/០១។ ទន្ទឹមនឹងនោះ ថ្ងៃសវនាការទាំងនោះ ឃ្លាតចន្លោះពីគ្នាដោយថ្ងៃឈប់សម្រាកថ្ងៃបុណ្យជាច្រើន ដោយមិនរាប់ថ្ងៃចុងសប្តាហ៍ ដែលក្នុងអំឡុងពេលនោះ មេធាវីការពារក្តីមិនអាចចូលមន្ទីរឃុំឃាំងឡើយ។

១៦. របាយការណ៍សុខភាពដែលធ្វើឡើងនៅខែមិនា ឆ្នាំ ២០១៤ ដែលតាមរយៈរបាយការណ៍នោះ អង្គជំនុំជម្រះបានកំណត់ប្រតិទិន "សម្រាល" របស់ខ្លួននោះ ក៏ជាការបញ្ឆោតមួយដែរ។ បរិបទដែលរបាយការណ៍នេះធ្វើឡើង ធ្វើឱ្យរបាយការណ៍នោះ មិនមានភាពប្រាកដប្រជា ដែលគេលែងប្រើ នោះគឺជាអ្វីដែលក្រុមមេធាវីការពារក្តីបានលើកឡើងតាំងពីពេលមុនម្ល៉េះ។[19] សេចក្តីនេះត្រូវបានឆ្លុះបញ្ចាំងឱ្យឃើញ ដោយការចូលសម្រាកក្នុងមន្ទីរពេទ្យពីរដងរបស់ លោក ខៀវ សំផន ក្នុងពេលក្រោយមកទៀត គឺលើកចុងក្រោយ នៅថ្ងៃទី១៦ ខែកញ្ញា កន្លងទៅនេះ ខណៈដែលលោកកំពុងតែ ធ្វើការលើបណ្តឹងសាទុក្ខរបស់លោក។

១៧. តែថា ប្រសិនបើអង្គជំនុំជម្រះរក្សាប្រតិទិននៃសវនាការដំបូងនៃសំណុំរឿង ០០២/០២ នៅថ្ងៃទី១៧ ខែតុលា នោះ លោក ខៀវ សំផន នឹងចំណាយម៉ោងពេលដ៏ច្រើនលើសវនាការ និងការរៀបចំចាំបាច់នានា ហើយលោកនឹងពេលតិចតួចសម្រាប់ធ្វើការលើបណ្តឹងសាទុក្ខ ប្រឆាំងនឹងសាលក្រមលើសំណុំរឿង ០០២/០១ ដែលជាចំណុចសំខាន់ព្រោះថាវានឹងជះឥទ្ធិពលទៅលើសំណុំរឿង ០០២/០២ ដែរ។ ជាការច្បាស់ណាស់ដែលថា ចំណាស់លោកទៅហើយ សមត្ថភាពផ្តង់អារម្មណ៍ និងគិតពិចារណា មិនដូចគ្នាទេ

---

[19] សារអេឡិចត្រូនិចនៃក្រុមមេធាវីការពារក្តី ជូនចំពោះអង្គជំនុំជម្រះ ក្រោមចំណងជើងថា "បន្ទាប់ពីរបាយការណ៍វេជ្ជសាស្ត្ររបស់ លោក ខៀវ សំផន" ថ្ងៃទី២៧ ខែមិនា ឆ្នាំ២០១៤ នៅម៉ោង ១១ម៉៤៦។ មានភ្ជាប់ក្នុងឧបសម្ព័ន្ធ។ សំណើជាបន្ទាន់សុំឱ្យពិចារណាឡើងវិញ លើដីកាកំណត់កាលបរិច្ឆេទសម្រាប់សវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០២

ប្រសិនជាប្រៀបធៀបការតាមដានការងារពីក្នុងមន្ទីរឃុំឃាំង តាមល្បឿនដំណើរការផ្ទាល់ខ្លួនរបស់លោក ជាមួយនឹងការចូលរួមពេញមួយថ្ងៃក្នុងសវនាការ ដែលលោកត្រូវត្រៀមរៀបចំមុនថែមទៀតផង។ ដោយមិននិយាយពីការប៉ះពាល់ដល់សុខភាពរបស់លោក លោក ខៀវ សំផន មិនអាចត្រូវដាក់ឲ្យប្រឈមទៅនឹងជម្រើសមួយ ក្នុងចំណោមនីតិវិធីពីរដំណាលគ្នា ដែលជម្រុញឲ្យលោក ត្រូវបោះបង់ចោលការការពារក្ដីរបស់លោកអស់មួយផ្នែកបានឡើយ។

១៨. ដូច្នេះ ការពិ ចារណាឡើងវិញលើដីកានេះ គឺពិតជាចាំបាច់ណាស់ ដើម្បីចៀសវាងការរំលោភរំលោភលើសិទ្ធិរបស់ លោក ខៀវ សំផន ក្នុងការទទួលបានការកាត់សេចក្ដីមួយប្រកបដោយយុត្តិធម៌។ ពីព្រោះថា តាមរយៈដីកានេះ អង្គជំនុំជម្រះបានរារាំងយ៉ាងជាក់ច្បាស់ ទៅនឹងការប្រើប្រាស់ប្រកបដោយប្រសិទ្ធិភាព និងជាក់ស្ដែងនូវសិទ្ធិរបស់លោក ខៀវ សំផន ក្នុងការធ្វើបណ្ដឹងសាទុក្ខប្រឆាំងនឹងការផ្ដន្ទាទោសលោក ហើយវាប៉ះពាល់ផងដែរដល់សិទ្ធិ ទទួលបានពេលវេលា និងមធ្យោបាយចាំបាច់សម្រាប់រៀបចំការការពារ ក្ដីរបស់លោក។ [20]

## ដីកាបណ្ដាលឲ្យបាត់សមភាពរវាងគូភាគី

១៩. បន្ទុកដ៏ធ្ងន់ក្នុងការទ្រាំទ្រនីតិវិធីពីរក្នុងពេលដំណាលគ្នា មិនត្រឹមតែជាការរំលោភលើសិទ្ធិរបស់ លោក ខៀវ សំផន ក្នុងការការពារខ្លួនប៉ុណ្ណោះទេ តែការជាការបំបាត់សមភាពនៃគូភាគីផងដែរ។ ភាពខុសគ្នានៃសមាសភាពក្រុមការងារ រវាងក្រុមមេធាវីការពារក្ដី និងការិយាល័យសហព្រះរាជអាជ្ញា ត្រូវបានរំឭកឡើងជាច្រើនលើកដោយមេធាវីការពារក្ដី។ ក្រៅពីចំនួនសហព្រះរាជអាជ្ញាដែលផ្លាស់វេនគ្នាធ្វើការនៅក្នុងសវនាការ ចំនួនកកម្មសិក្សាការីដ៏ច្រើនដែលសហព្រះរាជអាជ្ញាទទួលបាន មិនអាចប្រៀបបានទៅនឹងចំនួនកំណត់ដែលអនុញ្ញាតដល់ក្រុមមេធាវីការពារក្ដីឡើយ។ ច្រាសមកវិញ មេធាវីការពារក្ដីមានចំនួនពីររូប[21] សម្រាប់ជនជាប់ចោទម្នាក់ ហើយក្នុងពេលតែមួយ

[20] សេចក្ដីសម្រេច **E284/2/1/2** កថាខណ្ឌទី៦ និងកំណត់ជើងទំព័រទី១២ និងទី១៣។

[21] ???

ត្រៀមការសួរចម្លើយ និងអន្តរាគមន៍ផ្ទាល់មាត់ ចូលរួមក្នុងសវនាការ ហើយត្រូវសរសេរសារណានានាក្នុងអំឡុងពេលនៃនីតិវិធីទាំងមូល។ ពិតមែនតែការងារទាំងនេះត្រូវបានធ្វើឡើងដោយមានការចូលរួមយ៉ាងមានប្រសិទ្ធិភាព និងមានតម្លៃពីអ្នកពិគ្រោះយោបល់ ប៉ុន្តែអ្នកទាំងនោះមិនអាចពុះជ្រែកខ្លួន ឬបំពេញការងារជាច្រើនមុខក្នុងពេលតែមួយ ហើយក៏មិនអាចបំពេញការងារជាប់រហូតដែរហើយការងារខ្លះទៀតសោត ក៏មិនអាចផ្ទេរឱ្យពួកគេបានទៀត។

២០. ដូច្នេះ ការបង្ខំឱ្យក្រុមមេធាវីការពារក្តីបំពេញការងារសំខាន់ក្នុងបណ្តឹងសាទុក្ខផង ដោយចូលរួមក្នុងកិច្ចពិភាក្សាដេញដោលសម្រាប់សំណុំរឿង ០០២/០២ ផង មានន័យថាហាក់ដូចជាដាក់ក្រុមមេធាវីឱ្យស្ថិតក្នុងស្ថានភាពទាបជាងសហព្រះរាជអាជ្ញា។ ពីព្រោះថា សហព្រះរាជអាជ្ញាមានបន្ទុកការងារដែលត្រូវបំពេញតិចជាង នៅក្នុងបណ្តឹងសាទុក្ខ (បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាមានតែលើផ្នែកអង្គច្បាប់តែប៉ុណ្ណោះ *"ដើម្បីជាប្រយោជន៍ដល់ច្បាប់"*)។[22] ទាំងនេះធ្វើឱ្យសហព្រះរាជអាជ្ញាអាចពង្រឹងការងារខ្លួនសម្រាប់សំណុំរឿង ០០២/០២ ដូចជាដាក់ការស្នើសុំបន្ថែមនូវឯកសារថ្មីៗជាច្រើន (នៅចុងឆ្នាំ២០១៤!) ដែលក្រុមមេធាវីការពារក្តីមិនទាំងមានពេលពិនិត្យមើលផង។[23] ដូច្នេះ ដីកាសម្រេចរបស់អង្គជំនុំជម្រះផ្តល់អត្ថប្រយោជន៍ឱ្យសហព្រះរាជអាជ្ញា និងធ្វើឱ្យក្រុមមេធាវីការពារក្តីចុះខ្សោយ ក្នុងក្របខណ្ឌនៃមធ្យោបាយប្រើប្រាស់ដើម្បីជាតំណាង និងជួយជ្រោមជ្រែង លោក ខៀវ សំផន នៅក្នុងនីតិវិធី រីឯសហព្រះរាជអាជ្ញាក្នុង សំណុំរឿង ០០២ នឹងមានបន្ទុកការងារតិចជាង។

២១. វាជាការច្បាស់ណាស់ដែលថា ការថ្លឹងថ្លែងលើផលវិបាក រវាងការរក្សាប្រតិទិនដូចបានកំណត់ដោយអង្គជំនុំជម្រះ និងភាពចាំបាច់ក្នុងការកាត់សេចក្តីឱ្យបានឆាប់រហ័ស គឺជាហេតុផលសមគួរក្នុងការលើកកាលបរិច្ឆេទនៃសំណុំរឿង ០០២/០២ ទៅក្រោយពេល

---

[22] សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញា ស្តីពីបណ្តឹងសាទុក្ខចំពោះសេចក្តីសម្រេច នៅក្នុងសំណុំរឿង ០០២/០១ ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤ E313/3/1

[23] បញ្ជីឯកសារបន្ថែមសម្រាប់សវនាការ របស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៨០(៣) នៃវិធានផ្ទៃក្នុង ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៤ E313/3/1 (ជាមួយនឹងឧបសម្ព័ន្ធចំនួន៣ច្បាប់)

ដាក់សារណាបណ្តឹងសាទុក្ខ។ ពីព្រោះថា ធ្វើបែបនោះ សិទ្ធិនៃភាគីក្នុងការដឹកនាំការវិនិច្ឆ័យក្តីក្នុងថិរវេលាសមស្រប នឹងត្រូវអនុវត្តដោយមិនបង្កព្យសនកម្ម និងការខាតបង់ប្រយោជន៍ដល់ជនជាប់ចោទឡើយ។

## II. អំពីចំណុចសេសសល់ដែលត្រូវកំណត់ដើម្បីឲ្យសំណុំរឿង ០០២/០២ ដំណើរការល្អ

### បញ្ហាច្រានចោលក្រុមប្រឹក្សាជំនុំជម្រះសាលាដំបូងនៅមិនទាន់បានសម្រេចនៅឡើយ

២២. ម្យ៉ាងវិញទៀត វាជាការសំខាន់ណាស់ក្នុងការរំឭកថា មានចំណោទបញ្ហាមួយចំនួនដែលមិនទាន់បានដោះស្រាយ ស្តីពីបែបបទដំណើរការនៃសំណុំរឿង ០០២/០២។ ក្រុមមេធាវីការពារក្តីបានលើកឡើងរួចមកហើយថា ប្រសិនបើមិនព្យួរសំណុំរឿង ០០២/០២ ទេនោះ យើងខ្ញុំស្នើសុំឱ្យចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះថ្មីសម្រាប់វិនិច្ឆ័យក្តីក្នុងសំណុំរឿង ០០២/០២។ ការស្នើសុំបដិសេធចោលចៅក្រមមួយផ្នែកក្នុងអង្គជំនុំជម្រះ ក៏ត្រូវបានដាក់ស្នើឡើងដោយក្រុមមេធាវីការពារក្តី លោក នួន ជា ផងដែរ នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤។[24] ប្រសិនបើមិនមានគ្រោងទុកសំណេរស្តីពីការព្យួរនីតិវិធីក្នុងករណីបែបនេះទេ នោះហេតុផល និងការសន្សំពេលវេលាក្នុងការកាត់សេចក្តី នឹងត្រូវរង់ចាំសេចក្តីសម្រេចមួយដែលអាចទទួលលទ្ធផលមួយ គឺត្រូវត្រឡប់មកចាប់ផ្តើមសំណុំរឿង ០០២/០២ សាដើមឡើងវិញ។

### ភាគីនៅមិនទាន់បានដឹងនៅឡើយពីអ្វីដែលអង្គជំនុំជម្រះបច្ចុប្បន្ន ឬអង្គជំនុំជម្រះនាពេលខាងមុខចាត់ទុកថាបានពិភាក្សារួច

២៣. ម្យ៉ាងវិញទៀត ទោះបីជាមាន ឬមិនមានក្រុមប្រឹក្សាជំនុំជម្រះក៏ដោយ ក៏ភាគីនៅមិនទាន់បានដឹងនៅឡើយ ពីអ្វីដែលចាត់ទុកថាបានពិភាក្សារួច នៅក្នុងសំណុំរឿង០០២/០១

[24] *NUON Chea Application for Disqualification of Judges NIL Nonn, YA Sokhan, Jean-Marc LAVERGNE, and YOU Ottara* ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤ E314/6

ហើយមិនអាចយកមកពិភាក្សាជាថ្មី នៅក្នុងសំណុំរឿង០០២/០២[25] ឡើយ។ វាជាការច្បាស់ណាស់ដែលថាបញ្ហានេះជាប់ពាក់ព័ន្ធដោយផ្ទាល់ទៅនឹងខ្លឹមសារនៃសារណាបណ្តឹងសាទុក្ខរបស់ភាគី។ ពីព្រោះថា អង្គជំនុំជម្រះមិនអាចចាត់ទុកថាសេចក្តីសន្និដ្ឋានចេញពីបណ្តឹងសាទុក្ខថាជាអាជ្ញាអស់ជំនុំបានឡើយ ប្រសិនបើគ្មានការអះអាងបន្ថែមពីតុលាការកំពូលទេនោះ។ ដូច្នេះ សេចក្តីសម្រេចទាត់ចោល ឬមិនទាត់ចោលការជំទាស់ខាងមុខ អាចបង្ហាញឲ្យឃើញច្បាស់ លុះត្រាតែមានសម្អាងហេតុ និងអំណះអំណាងក្នុងបណ្តឹងសាទុក្ខរបស់ភាគី។

## អង្គជំនុំជម្រះមិនបានសម្រេចលើការជំទាស់ប្រឆាំងនឹងព្រះរាជអាជ្ញា និងសហមេធាវីនៃដើមបណ្តឹងរដ្ឋប្បវេណី

២៤. ក្រុមមេធាវីការពារក្តីគិតទុកមុនពីការពិភាក្សាដេញដោលដ៏កក្រើករំពើកនៃនីតិវិធី ទៅលើអ្វីដែលសហព្រះរាជអាជ្ញាមានបំណងយកធ្វើជាភស្តុតាង សម្រាប់សំណុំរឿង ០០២/០២។ អង្គជំនុំជម្រះមិនបានផ្តល់ហេតុផលសម្អាងទៅលើការជំទាស់ដែលលើកឡើងដោយក្រុមមេធាវីការពារក្តី[26] ពាក់ព័ន្ធនឹងបញ្ជីឈ្មោះសាក្សីផ្តល់ដោយសហព្រះរាជអាជ្ញា នៅឡើយ។ ទាំងនេះជាចំណុចសំខាន់ដែលត្រូវសម្រេចជាមុន ដើម្បីឲ្យភាគីរៀបចំខ្លួនបានត្រឹមត្រូវ ក្នុងក្របខណ្ឌនៃការស៊ើបសួរនៅថ្ងៃខាងមុខ។ ក្រុមមេធាវីការពារក្តីពិតជាចង់ឲ្យការផ្តល់ហេតុផលនៃការទាត់ចោល ឬការទទួលយកសាក្សីមិនយឺតយ៉ាវដូចសេចក្តីលើសាក្សីដែលត្រូវកោះអញ្ជើញក្នុងសំណុំរឿង០០២/០១ ដែលបានបង្ហាញនៅថ្ងៃចេញសាលក្រមតែម្តង។[27] ម៉្យាងទៀត នោះគឺជាបណ្តឹងដែលបានរំឭកនៅក្នុង

---

[25] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និង វិសាលភាពនៃសំណុំរឿង ០០២/០២ E301/9/1ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៤។ ឯកសារ E305/9 (“ការជំទាស់ E305/9”) កថាខណ្ឌ ២៨-៣១ ។ ការបង្ហាញពីបញ្ហាអង្គច្បាប់ដែលមេធាវីការពារក្តីលោក ខៀវ សំផន មានបំណងលើកឡើងនៅក្នុងសវនាការបឋមសម្រាប់សំណុំរឿង ០០២/០២ ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៤ **E305/11** កថាខណ្ឌទី៧ ។ ឯកសារស្នើឡើងដោយមេធាវីការពារក្តីលោក ខៀវ សំផន សម្រាប់សំណុំរឿង ០០២/០២ ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤ **E305/12** កថាខណ្ឌទី ២២-២៣ និងទី២៦។

[26] ការជំទាស់ E305/9

[27] សេចក្តីសម្រេចស្តាពរស្តីពីសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវស្តាប់សក្ខីកម្មនៅក្នុងសំណុំរឿងសំណើជាបន្ទាន់សុំឲ្យពិចាណាការឡើងវិញ លើដីកាកំណត់កាលបរិច្ឆេទសម្រាប់សវនាការលើអង្គសេចក្តីក្នុងសំណុំរឿង

ក្របខណ្ឌនៃបណ្ដឹងសាទុក្ខលើសាលក្រម។

**ជនជាប់ចោទនៅតែមិនទាន់ដឹងពីតើអង្គហេតុដែលមិនបានបញ្ចូលក្នុងសំណុំរឿង០០២/០២ នៅជាយ៉ាងណា**

២៥. នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួន ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤[28] ថ្វីត្បិតតែបានព្យួរជាបណ្ដោះអាសន្ននូវបន្ទុកដែលមិនទាន់បញ្ចូលក្នុងសំណុំរឿង០០២/០២ ក្ដី អង្គជំនុំជម្រះតុលាការកំពូលបានរំឭកថា អង្គជំនុំជម្រះសាលាដំបូងមានករណីយកិច្ចកំណត់រាល់បន្ទុកដែលខ្លួនទទួលបានក្នុងបណ្ដឹង។ នៅពេលមុននោះ បើទោះបីជាគម្រោងវិសោធនកម្មលើទបញ្ជាផ្ទៃក្នុង ត្រូវបានបង្ហាញក្រោយមក ដោយសហព្រះរាជអាជ្ញា ទៅកាន់គណៈកម្មាធិការនីតិវិធី ជាមួយនឹងការជំទាស់មួយចំនួនរបស់មេធាវីការពារក្ដី ដែលត្រូវបង្ហាញជូនតាមរយៈអង្គភាពគាំពារការការពារក្ដី យ៉ាងណាក្ដី រហូតមកដល់ថ្ងៃនេះមិនទាន់មានអ្វីដែលបានសម្រេចនៅឡើយ រីឯសហព្រះរាជអាជ្ញានៅតែមិនច្បាស់លាស់អំពីបែបបទនៃការវិនិច្ឆ័យបន្ទុកដែលនៅសេសសល់នោះឡើយ។ វាជាចំណុចដ៏សំខាន់ដែលត្រូវដោះស្រាយ មុនចាប់ផ្ដើមសំណុំរឿង០០២/០២ ពីព្រោះថាបើនិយាយពីការជំទាស់នៅក្នុងកិច្ចពិភាក្សាដេញដោល និងយុទ្ធសាស្ត្រក្នុងការការពារក្ដី វាជារឿងសំខាន់ណាស់។

២៦. រាល់ចំណុចដែលត្រូវពិភាក្សា និងសម្រេចជាមុន មុនចាប់ផ្ដើមសំណុំរឿង០០២/០២ នេះក៏ជាការគប្បីកុំកំណត់ការផ្ដើមធ្វើសវនាការ នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ ២០១៤ ហើយទោះជាយ៉ាងណា មិនត្រូវធ្វើមុនដាក់សារណាបណ្ដឹងសាទុក្ខលើសាលក្រមឡើយ។

---

០០២/០១ ថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ **E312**

[28] សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗ របស់ ខៀវ សំផន ប្រឆាំងនឹងសេចក្ដីសម្រេច របស់អង្គជំនុំជម្រះសាលាដំបូង លើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤ **E301/9/1/1/3** កថាខណ្ឌ ៨៩-៩០

២៧. **អាស្រ័យហេតុនេះ** ក្រុមមេធាវីការពារក្តីរបស់ លោក ខៀវ សំផន ស្នើសុំអង្គជំនុំជម្រះមេត្តា

- ពិនិត្យឡើងវិញនូវ *"ដីកាកំណត់កាលបរិច្ឆេទសម្រាប់សវនាការលើអង្គសេចក្តីក្នុងសំណុំរឿង០០២/០២"*[29] ដែលកំណត់ការចាប់ផ្តើមសំណុំរឿង០០២/០២ នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ ២០១៤ ។
- ជូនព័ត៌មាន និងវិនិច្ឆ័យថាការចាប់ផ្តើមសវនាការ នឹងត្រូវកំណត់នៅកាលបរិច្ឆេទក្រោយ ដាក់សារណាបណ្តឹងសាទុក្ខលើសាលក្រមដែលប្រកាសថ្ងៃទី៧ ខែសីហា ឆ្នាំ ២០១៤ ពាក់ព័ន្ធនឹង សំណុំរឿង០០២/០១។
- សម្រេចឱ្យក្រុមមេធាវីការពារក្តី ស្តីពីអ្វីដែលមេធាវីរក្សាការស្នើសុំ ដើម្បីឱ្យចៅក្រម និល ណុន ចៅក្រម Sylvia CARTWRIGHT ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE ចៅក្រម យូ ឧត្តរា និងចៅក្រម Claudia FENZ ត្រូវជំនួសដោយក្រុមប្រឹក្សាជំនុំជម្រះថ្មីដែលមានបេសកកម្មវិនិច្ឆ័យក្តី ក្នុងសំណុំរឿង០០២/០២ ដោយឥតលម្អៀង ដោយអនុវត្តតាមវិធាន៣៤ នៃវិធានផ្ទៃក្នុង។

**ហើយទោះជាយ៉ាងណា**

- ព្យួរនីតិវិធីក្នុងសំណុំរឿងសំណុំរឿង០០២/០២ ដរាបណាមិនទាន់បានសម្រេចលើការស្នើសុំមុនៗទាំងស្រុងនោះទេ។

**រក្សាសិទ្ធិកែប្រែគ្រប់យ៉ាង**
**និងដើម្បីយុត្តិធម៌**

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន<br>មេធាវី Anta GUISSÉ<br>មេធាវី Arthur VERCKEN | ភ្នំពេញ<br>ប៉ារីស<br>ប៉ារីស | |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |

[29] ដីកាសម្រេច **E316**
សំណើជាបន្ទាន់សុំឱ្យពិចារណាឡើងវិញ លើដីកាកំណត់កាលបរិច្ឆេទសម្រាប់សវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០២